នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Sep-2012, 14:18
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ស.ដ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**មតិតបនឹងសំណើរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ផ្ញើសំណើ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត សុំការបញ្ជាក់អំពីអត្ថិភាពឯកសារសម្លេង នៃការស្តាប់ចម្លើយសាក្សី អៀង តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨**

---

ដាក់ដោយ៖

**សហមេធាវីការពារក្តីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

លោក Jacques VERGES

**ជំនួយការ៖**

អ្នកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

ផ្ញើជូន៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. កាលពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តី លោក អៀង សារី បានដាក់សំណើមួយស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពីការិយាល័យសហចៅក្រមស៊ើបអង្កេត អំពីអត្ថិភាពឯកសារសម្លេងនៃការស្តាប់ចម្លើយសាក្សី លោក អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨[1]។

២. តាមរយៈមតិគាំទ្រនេះ លោក ខៀវ សំផន មានបំណងគាំទ្រសំណើ លោក អៀង សារី និងឯកភាពទាំងស្រុងលើរាល់ទឡ្ហីករណ៍ទាំងឡាយដែលបានលើកឡើងដោយសហមេធាវីរបស់លោក អៀង សារី[2]។ ពេលនេះក៏ជាឱកាសសម្រាប់ឲ្យ លោក ខៀវ សំផន បង្ហាញសាជាថ្មីនូវការមិនជឿជាក់របស់ខ្លួនទៅលើសុចរិតភាពនៃនីតិវិធីអនុវត្តដោយអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត។

៣. លោក ខៀវ សំផន មានបំណងរំលឹកដល់អង្គជំនុំជម្រះសាលាដំបូងផងដែរ ពីភាពសង្ស័យដែលលោកធ្លាប់បានលើកឡើង ពាក់ព័ន្ធនឹងកាលៈទេសៈនៃការស្តាប់ចម្លើយសាក្សី លោក ភី ភួន[3]។ ទន្ទឹមគ្នានេះដែរ លោក ខៀវ សំផន ក៏មានបំណងសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ចាប់អារម្មណ៍ជាពិសេសទៅលើភាពមិនស៊ីសង្វាក់គ្នារវាងពាក្យសំដីក្នុងប្រតិចារឹក និងកាលបរិច្ឆេទផ្លូវការនៃការស្តាប់ចម្លើយសាក្សី លោក នង សុផង់ ដែលលោកមេធាវី

---

[1] *សំណើរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី ក.ស.ច.ស អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតសម្លេងនានា ទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨,* ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ឯកសារ **E224** ជូនដំណឹងថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២។

[2] លើកលែងតែមានការបកប្រែសំណើនេះជាភាសាបារាំង។

[3] *មតិគាំទ្រសំណើរបស់លោក អៀង សារី E221 និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឲ្យបង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីសាក្សីកម្មជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោល ជំនួសឲ្យសាក្សីកម្មផ្ទាល់មាត់* ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ឯកសារ **E223**។

ការបំភ្លឺពាក់ព័ន្ធនឹងការស្តាប់ចម្លើយ លោក នង សុផង់ និងបន្តអនុវត្តនីតិវិធីបែប នេះលើរាល់ការស្តាប់ចម្លើយសាក្សីទាំងអស់ ដែលការកត់ត្រាពាក្យសំដីរបស់ពួក គេ មានភាពមិនស៊ីសង្វាក់គ្នា។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ភ្នំពេញ<br><br>ប៉ារីស<br><br>ប៉ារីស<br><br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |